ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្រមខណ្ឌគុណសម្បទា
# របស់
# គ្រូប្រឹក្សាតាមសាលារៀន

នាយកដ្ឋានគម្រង់ទិសវិជ្ជាជីវៈ
ឆ្នាំ២០២១

# មាតិកា


**បុព្វកថា** ........ ii

**១. សេចក្តីផ្តើម** ........ 1

**២. គោលបំណង** ........ 2

**៣. អត្ថប្រយោជន៍** ........ 2

**៤. សមាសភាគ** ........ 2

**៤.១. ចំណេះដឹង និងបទពិសោធន៍** ........ 2

៤.១.១ ការបណ្តុះបណ្តាលបន្ត ........ 2

៤.១.២ ការបណ្តុះបណ្តាលដំបូង ........ 3

**៤.២. ភារកិច្ច និងការទទួលខុសត្រូវ** ........ 3

៤.២.១. ភារកិច្ច និងការទទួលខុសត្រូវមូលដ្ឋាន ........ 3

ក. ការអនុវត្តគោលការណ៍ណែនាំ ........ 3

ខ. ឥទ្ធិពល និងអន្តរាគមន៍ផ្អែកលើទិន្នន័យ ........ 3

គ. ការអភិវឌ្ឍវិជ្ជាជីវៈ ........ 4

ឃ. ការផ្តល់របាយការណ៍អំពីភារកិច្ច និងទំនួលខុសត្រូវ ........ 4

៤.២.២. ភារកិច្ច និងការទទួលខុសត្រូវផ្នែកបច្ចេកទេស ........ 4

ក. សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់រៀន ........ 4

ខ. សេវាប្រឹក្សាទល់មុខ ........ 4

គ. សេវាការងារបណ្តាញ ........ 5

**៤.៣. គុណសម្បទារបស់គ្រូប្រឹក្សាតាមសាលារៀន** ........ 6

៤.៣.១. គុណសម្បទាមូលដ្ឋាន ........ 6

៤.៣.២. គុណសម្បទាផ្នែកបច្ចេកទេស ........ 6

**៤.៤ ក្រមសីលធម៌វិជ្ជាជីវៈគ្រូប្រឹក្សាតាមសាលារៀន** ........ 7

៤.៤.១ ក្រមសីលធម៌ចំពោះសិស្ស ........ 7

៤.៤.២ ក្រមសីលធម៌ចំពោះគ្រឹះស្ថានសិក្សា និងសហការីរួមអាជីព ........ 8

៤.៤.៣ ក្រមសីលធម៌ចំពោះមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស  និងសហគមន៍ ........ 8

៤.៤.៤ ក្រមសីលធម៌ចំពោះវិជ្ជាជីវៈ និងខ្លួនឯង ........ 9

**៤.៥ លទ្ធផលការងារ** ........ 9

**ឯកសារយោង៖** ........ 11

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងសកម្មភាពនានាពាក់ព័ន្ធនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ កម្មវិធីអប់រំបំណិនជីវិត កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាជាដើម សំដៅលើកកម្ពស់ការអភិវឌ្ឍន៍ជំនាញដល់យុវជនឱ្យមានលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា ស្មារតី សីលធម៌ តម្លៃ បំណិន ជំនាញ ដើម្បីឱ្យពួកគេក្លាយជាពលរដ្ឋល្អក្នុងសង្គម ព្រមទាំងចូលរួមចំណែកក្នុងការអភិវឌ្ឍគ្រួសារ សហគមន៍ និងប្រទេសជាតិ ដោយស្មារតីបន្តការសិក្សាពេញមួយជីវិត និងស្របតាមចតុស្តម្ភទាំង៤ គឺ រៀនដើម្បីមានចំណេះដឹង រៀនដើម្បីមានចំណេះធ្វើ រៀនដើម្បីឱ្យក្លាយជាពលរដ្ឋល្អ និងរៀនដើម្បីរួមរស់ជាមួយគ្នា។

ក្នុងគោលដៅអភិវឌ្ឍជំនាញដល់យុវជនកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យអនុវត្តនូវកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមគ្រឹះស្ថានមធ្យមសិក្សា និងបានកសាងនូវធនធានចាំបាច់ ដូចជាការបណ្តុះបណ្តាលគ្រូប្រឹក្សាតាមសាលារៀន និងសៀវភៅសិក្សាផ្នែកបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ជាដើម។ ទន្ទឹមនឹងការរៀបចំនូវធនធានទាំងនេះ ក្រសួង បានកសាង "ឯកសារក្របខណ្ឌគុណសម្បទារបស់គ្រូប្រឹក្សាតាមសាលារៀន" ដើម្បីឱ្យអ្នកពាក់ព័ន្ធអាចប្រើប្រាស់ ក្នុងគោលដៅអភិវឌ្ឍកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា ឱ្យកាន់តែរឹងមាំ និងប្រកបដោយនិរន្តរភាព។

ឯកសារក្របខណ្ឌគុណសម្បទារបស់គ្រូប្រឹក្សាតាមសាលារៀន ត្រូវបានរៀបចំឡើងដោយបែងចែកជាសមាសភាគ ចំនួន៥ គឺ ១) ចំណេះដឹង និងបទពិសោធន៍ដែលទាមទារ ២) ភារកិច្ច និងការទទួលខុសត្រូវ ៣) គុណសម្បទា ៤) ក្រមសីលធម៌ និង ៥) លទ្ធផលការងារ។ ការបំពេញបាននូវសមាសភាគទាំង៥នេះ បូករួមនឹងឆន្ទៈស្រឡាញ់ពេញចិត្តក្នុងការបំពេញកិច្ចការងាររបស់គ្រូប្រឹក្សាតាមសាលារៀន នឹងធ្វើឱ្យការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅតាមសាលារៀន ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដល់នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ និងមន្ត្រីជំនាញ ដែលបានកសាងឯកសារនេះឡើង ព្រមទាំងអង្គការជំនួយព្រះវិហារហ្វាំងឡង់ (FCA) ដែលបានសហការផ្តល់ធាតុចូលដ៏មានតម្លៃ និងបានជួយជំរុញការអនុវត្ត ក៏ដូចជាការពង្រឹងនិងពង្រីកកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សានៅតាមសាលារៀន ឱ្យកាន់តែមានភាពល្អប្រសើរ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា ភាគីពាក់ព័ន្ធទាំងអស់ នឹងប្រើប្រាស់ "ឯកសារក្របខណ្ឌគុណសម្បទារបស់គ្រូប្រឹក្សាតាមសាលារៀន" នេះ ដើម្បីអភិវឌ្ឍកិច្ចការរបស់ខ្លួន ដោយផ្អែកលើក្របខណ្ឌគោលនេះ ប្រកបដោយស្មារតីចូលរួម និងទទួលខុសត្រូវខ្ពស់។

ថ្ងៃ សុក្រ ៨រោច ខែ បឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ កក្កដា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

## ១. សេចក្ដីផ្ដើម

កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា គឺជាចង្កោមកម្មវិធី ដែលជួយត្រួសត្រាយផ្លូវ និងផ្ដល់ការគាំទ្រដល់កុមារ យុវជនលើដំណើរការសិក្សារៀនសូត្រ ការសម្រេចចិត្តជ្រើសរើសផ្លូវសិក្សា អាជីព និងមុខរបរ ការរៀបចំឥរិយាបថ បំពេញការងារ ដោយផ្អែកលើទេពកោសល្យ សមត្ថភាព ចំណាប់អារម្មណ៍ បំណិន និងសក្ដានុពលទីផ្សារការងារ។ កម្មវិធីនេះ ត្រូវបានអនុវត្តយ៉ាងទូលំទូលាយ ក្នុងបណ្ដាប្រទេសជាច្រើនស្របតាមបរិបទសង្គមវប្បធម៌ និងសេដ្ឋកិច្ច និងក្នុងទម្រង់ផ្សេងៗគ្នាពីប្រទេសមួយទៅប្រទេសមួយ។

ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្ដើមអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សានៅឆ្នាំ ២០១៥ និងបានរៀបចំយន្តការបណ្ដុះបណ្ដាលគ្រូប្រឹក្សាតាមសាលារៀន ស្របតាមបរិបទកម្ពុជា ដើម្បីធានាបាននូវការកសាងធនធាននិងការពង្រាយគ្រូប្រឹក្សាតាមសាលារៀននៅតាមគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងការបំពាក់បំប៉ននូវសមត្ថភាពជំនាញវិជ្ជាជីវៈដល់គ្រូ សម្រាប់គាំទ្រដល់ដំណើរការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សាប្រកបដោយនិរន្តរភាព។

ក្នុងយន្តការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សានៅតាមគ្រឹះស្ថានមធ្យមសិក្សា គ្រូប្រឹក្សាតាមសាលារៀន គឺជាអ្នករៀបចំនិងអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សា ដែលជាកម្មវិធីមួយជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ កម្មវិធីនេះ មានភាពច្បាស់លាស់លើវិសាលភាពអនុវត្ត និងត្រូវបានរៀបចំឡើងក្នុងទម្រង់គាំពារសិស្ស ព្រមទាំងមានលក្ខណៈគាំទ្រការវិវឌ្ឍរបស់សិស្ស។ ដើម្បីសម្រេចបាននូវប្រសិទ្ធភាពកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្ដល់ប្រឹក្សាជាអតិបរមា ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំផលធៀបគ្រូប្រឹក្សាតាមសាលារៀនម្នាក់សិស្ស២៥០នាក់ (១:២៥០) និងសេវាការងារស្នូលចំនួន ៣ គឺ (១) សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់ (២) សេវាប្រឹក្សាទល់មុខ និង (៣) សេវាការងារបណ្ដាញ ដែលគ្រូប្រឹក្សាតាមសាលារៀនជាអ្នកដឹកនាំ និងរៀបចំសេវាទាំងនេះ។ សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់រៀន តម្រូវឱ្យគ្រូរៀបចំសកម្មភាពតម្រង់ទិសការសិក្សា និងសកម្មភាពបង្រៀននៅក្នុងថ្នាក់រៀនអំពីផែនការសិក្សា និងផែនការអាជីពនិងមុខរបរ។ សេវាប្រឹក្សាទល់មុខ តម្រូវឱ្យគ្រូការសហការជាមួយអ្នកពាក់ព័ន្ធក្នុងអង្គភាព ដើម្បីរៀបចំក្រុមសិស្សសម្រាប់ផ្ដល់ការប្រឹក្សាទល់មុខ និងការប្រចាំការក្នុងបន្ទប់ប្រឹក្សាយោបល់ ដើម្បីរង់ចាំផ្ដល់ជំនួយដល់សិស្សដែលត្រូវការការប្រឹក្សាយោបល់ទល់មុខ។ សេវាការងារបណ្ដាញ តម្រូវឱ្យគ្រូទំនាក់ទំនង និងសហការជាមួយអ្នកពាក់ព័ន្ធក្នុងអង្គភាព និងក្នុងសហគមន៍ ដើម្បីប្រមូលទិន្នន័យ និងផ្ដល់អន្តរាគមន៍ណាមួយដល់សិស្ស នៅពេលដែលមានតម្រូវការ និងការព្រមព្រៀងគ្នារវាងគ្រូនិងសិស្ស។

ក្នុងន័យបំពេញបាននូវភាពរួមក្នុងការកំណត់លក្ខខណ្ឌចាំបាច់នានាសម្រាប់ក្រុមគោលដៅ ដែលនឹងត្រូវក្លាយខ្លួនជាគ្រូប្រឹក្សាតាមសាលារៀន អាចអនុវត្តបាននូវភារកិច្ចដូចបានរៀបរាប់ខាងលើ ក៏ដូចជាបន្ទឹលក្ខខណ្ឌបច្ចេកទេសមួយចំនួន ដែលអាចអនុវត្តបានក្នុងបរិបទសាលារៀន ការរៀបចំឯកសារក្របខណ្ឌគុណសម្បទារបស់គ្រូប្រឹក្សាតាមសាលារៀន គឺជាការចាំបាច់ចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ២. គោលបំណង

ក្របខណ្ឌគុណសម្បទារបស់គ្រូប្រឹក្សាតាមសាលារៀន ត្រូវបានកសាងឡើងជាក្របខណ្ឌសមត្ថភាពជាក់លាក់មួយ ដើម្បីឱ្យគ្រូប្រឹក្សាតាមសាលារៀនអនុវត្តសេវានានារបស់កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដល់សិស្សប្រកបដោយគុណភាព។ ក្របខណ្ឌគុណសម្បទានេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើតម្រូវការចាំបាច់ជាក់ស្តែង ស្របតាមបរិបទរបស់ប្រទេសកម្ពុជា ហើយត្រូវប្រើប្រាស់ជាឯកសារយោងសម្រាប់កម្មវិធីអភិវឌ្ឍសមត្ថភាពអ្នកពាក់ព័ន្ធផ្នែកមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ជាពិសេសសំដៅដល់ការកសាងសមត្ថភាពគ្រូប្រឹក្សាតាមសាលារៀន។

## ៣. អត្ថប្រយោជន៍

ក្របខណ្ឌគុណសម្បទារបស់គ្រូប្រឹក្សាតាមសាលារៀននេះ នឹង៖

- ផ្តល់ទស្សនវិស័យរួមសម្រាប់កសាង អភិវឌ្ឍ និងលើកកម្ពស់សមត្ថភាពគ្រូប្រឹក្សាតាមសាលារៀនក្នុងប្រទេសកម្ពុជា ដោយផ្តោតសំខាន់លើការកែលម្អលទ្ធផលសិក្សារបស់សិស្ស
- ធានាថាសិស្សទាំងអស់ទទួលបានសេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាប្រកបដោយគុណភាព និងសមធម៌
- កំណត់បាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលគ្រូប្រឹក្សាតាមសាលារៀនត្រូវមាន និងត្រូវអភិវឌ្ឍជាប្រចាំ។

## ៤. សមាសភាគ

ក្នុងគោលដៅធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅតាមគ្រឹះស្ថានសិក្សា ក្របខណ្ឌគុណសម្បទាសម្រាប់គ្រូប្រឹក្សាតាមសាលារៀន ត្រូវបានកំណត់សមាសភាគចំនួន ៦ ដូចខាងក្រោម៖

- ចំណេះដឹង និងបទពិសោធន៍
- ភារកិច្ច និងការទទួលខុសត្រូវ
- គុណសម្បទារបស់គ្រូប្រឹក្សាតាមសាលារៀន
- ក្រមសីលធម៌របស់គ្រូប្រឹក្សាតាមសាលារៀន
- លទ្ធផលការងារ។

### ៤.១. ចំណេះដឹង និងបទពិសោធន៍

គ្រូប្រឹក្សាតាមសាលារៀនត្រូវមានគុណវុឌ្ឍិស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

#### ៤.១.១ ការបណ្តុះបណ្តាលបន្ត

- ជាបុគ្គលិកអប់រំចាប់ពីក្របខណ្ឌ«ខ» ឡើង
- មានទំនាក់ទំនង និងទំនាក់ទំនងអន្តរបុគ្គលល្អ
- មានបទពិសោធន៍បង្រៀនរយៈពេល២ឆ្នាំ
- ស្រឡាញ់ចូលចិត្តធ្វើការងារជាមួយសិស្ស និងសហគមន៍

- យល់ដឹងអំពីនិន្នាការទីផ្សារការងារនាពេលបច្ចុប្បន្ននិងអនាគត
- យល់ដឹងអំពីគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ប្រើប្រាស់បច្ចេកវិទ្យានិងទំនាក់ទំនងព័ត៌មានវិទ្យា (ICT) បាន
- ស្តាប់ និយាយ និងសរសេរ ភាសាអង់គ្លេស បានខ្លះៗ គឺជាការប្រសើរ។

#### ៤.១.២ ការបណ្តុះបណ្តាលដំបូង

- មានសញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាបត្រឡើង ផ្នែកសង្គមសាស្ត្រ
- មានទំនាក់ទំនង និងទំនាក់ទំនងអន្តរបុគ្គលល្អ
- ស្រឡាញ់ចូលចិត្តធ្វើការងារជាមួយសិស្ស និងសហគមន៍
- យល់ដឹងអំពីនិន្នាការទីផ្សារការងារនាពេលបច្ចុប្បន្ននិងអនាគត
- យល់ដឹងអំពីគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ប្រើប្រាស់បច្ចេកវិទ្យានិងទំនាក់ទំនងព័ត៌មានវិទ្យា (ICT) បាន
- ស្តាប់ និយាយ និងសរសេរ ភាសាអង់គ្លេស បានខ្លះៗ គឺជាការប្រសើរ។

## ៤.២. ភារកិច្ច និងការទទួលខុសត្រូវ

កិច្ចការទូទៅ ភារកិច្ចនិងទំនួលខុសត្រូវពាក់ព័ន្ធ និងសកម្មភាពសំខាន់ៗ ដែលជាការងាររបស់គ្រូប្រឹក្សាតាមសាលារៀន ត្រូវបានរៀបចំឡើងទៅតាមបែបបទ និងវិសាលភាពកិច្ចការរបស់គ្រូប្រឹក្សាតាមសាលារៀន ដោយស្ថិតនៅក្នុងដែនកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។

#### ៤.២.១. ភារកិច្ច និងការទទួលខុសត្រូវមូលដ្ឋាន

#### ក. ការអនុវត្តគោលការណ៍ណែនាំ

- ដឹកនាំ រៀបចំ និងអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា ស្របតាមការណែនាំរបស់ក្រសួងរបស់ក្រសួងអប់រំ យុវជន និងកីឡា
- អនុវត្តគោលការណ៍រក្សាការណ៍សម្ងាត់តាមលក្ខន្តិកៈកំណត់
- អនុវត្តកាតព្វកិច្ច និងប្រកបដោយក្រមសីលធម៌ ជាមួយសិស្ស មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស គណៈគ្រប់គ្រង សហការី អាជ្ញាធរ និងភាគីពាក់ព័ន្ធ។

#### ខ. ឥទ្ធិពល និងអន្តរាគមន៍ផ្អែកលើទិន្នន័យ

- ប្រមូល និងប្រើប្រាស់ទិន្នន័យរបស់សិស្សដែលពាក់ព័ន្ធ ដើម្បីតាមដានលទ្ធផលសិក្សា និងដើម្បីកំណត់នឹងផ្តល់ការគាំទ្រដល់សិស្សដែលមិនទាន់បានឈានដល់កម្រិតដែលរំពឹងទុកដោយកត្តាឧបសគ្គនានា ឬកត្តាធនធានមិនគ្រប់គ្រាន់សម្រាប់ការសិក្សា ជាដើម
- ប្រើប្រាស់ទិន្នន័យដែលទទួលបានពីកម្មវិធីមគ្គុទ្ទេសក៍និងការផ្តល់ប្រឹក្សា និងពីសកម្មភាពពាក់ព័ន្ធនានា ដើម្បីបង្ហាញអំពីផលជះរបស់កម្មវិធី លើលទ្ធផលនៃការសិក្សា និងការវិវឌ្ឍនៃផែនការជីវិតរបស់សិស្ស និងជាមូលដ្ឋានក្នុងការសម្រេចចិត្តនានា។

### គ. ការអភិវឌ្ឍវិជ្ជាជីវៈ

- ធ្វើបច្ចុប្បន្នភាពបំណិន និងចំណេះដឹង តាមរយៈការបន្តអភិវឌ្ឍវិជ្ជាជីវៈ និងប្រើប្រាស់ធនធាននានា សម្រាប់ទទួលបានព័ត៌មាន ក៏ដូចជាគំនិតថ្មីៗបន្ថែម ដើម្បីអភិវឌ្ឍការងារគ្រូប្រឹក្សាតាមសាលារៀន និងដើម្បីអាចឆ្លើយតបបានទៅនឹងតម្រូវការប្រែប្រួលដ៏លឿននៃពិភពការងារ និងមជ្ឈដ្ឋានប្រតិបត្តិការងារ
- កសាងបណ្ដាញ និងក្រុមដែលមានវិជ្ជាជីវៈដូចគ្នា ជាមួយគ្រូប្រឹក្សាតាមសាលារៀនផ្សេងទៀត ដើម្បីពង្រឹងចំណេះដឹង និងចែករំលែកបទពិសោធន៍ និងជានានូវប្រសិទ្ធភាពនិងនិរន្តរភាពក្នុងការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- ផ្តល់ការជួយគាំទ្រដល់គរុនិស្សិតហាត់ការ និងគ្រូប្រឹក្សាតាមសាលារៀន ដែលទើបចេញថ្មីតាមរយៈសកម្មភាពបង្វឹកនៅនឹងកន្លែង។

### ឃ. ការផ្តល់របាយការណ៍អំពីតារកិច្ច និងទំនួលខុសត្រូវ

- កត់ត្រារបាយការណ៍ជំនួបទល់មុខជាមួយសិស្សឱ្យបានមត់គត់
- ផ្តល់របាយការណ៍ទៀងទាត់តាមឋានានុក្រមជូននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ
- ផ្សព្វផ្សាយផែនការការងារមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា និងរបាយការណ៍វឌ្ឍនភាពការងារ ជាមួយសហការីក្នុងសាលារៀន។

## ៤.២.២. តារកិច្ច និងការទទួលខុសត្រូវផ្នែកបច្ចេកទេស

### ក. សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់រៀន

សមត្ថភាពកសាង រៀបចំ និងដឹកនាំសេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់រៀនៈ

- ផ្តល់សេវាបង្រៀនក្នុងថ្នាក់រៀន ទៅតាមកម្រិតថ្នាក់ដែលគណៈគ្រប់គ្រងសាលារៀនរៀបចំជូន
- រៀបចំកិច្ចតែងការបង្រៀន ស្របតាមកម្មវិធីក្នុងសៀវភៅដែលផលិតដោយក្រសួងអប់រំ យុវជន និងកីឡា
- កសាងសម្ភារសិក្សានានាសម្រាប់សេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់
- ផ្តួចផ្តើមសកម្មភាពសិក្សា និងបច្ចេកទេសបង្រៀនស្របតាមតម្រូវការរបស់សិស្ស និងគោលដៅរបស់សាលារៀន។

### ខ. សេវាប្រឹក្សាទល់មុខ

សមត្ថភាពកសាង រៀបចំ និងដឹកនាំសេវាប្រឹក្សាទល់មុខៈ

- កសាង រៀបចំ និងដឹកនាំសេវាប្រឹក្សាទល់មុខ
- ប្រើប្រាស់បំណិនផ្តល់ប្រឹក្សាក្នុងពេលប្រឹក្សាទល់មុខ
- ប្រើប្រាស់បំណិនផ្តល់ប្រឹក្សាប្រកបដោយសីលធម៌ និងស្របតាមគោលការណ៍វិជ្ជាជីវៈ

- បំពេញកិច្ចការងារក្នុងព្រំដែនវិជ្ជាជីវៈ
- ផ្តល់ការយកចិត្តទុកដាក់ និងការគាំពារសមស្រប
- វាយតម្លៃ កំណត់ និងឆ្លើយតបចំពោះហានិភ័យ និងភាពបន្ទាន់
- ប្រើប្រាស់ការណែនាំ និងជំនួយបែបវិជ្ជាជីវៈ
- អនុវត្តបំណិនផ្តល់ប្រឹក្សាក្នុងការស្វែងយល់អំពីសិស្សដោយប្រើប្រាស់ការយល់ដឹងអំពីសមានចិត្ត
- ប្រើប្រាស់បំណិនផ្តល់ប្រឹក្សា ប្រកបដោយការយល់ចិត្តចំពោះសិស្សគ្រប់កម្រិតថ្នាក់ ពណ៌សម្បុរ ភេទ សាសនា
- ប្រើប្រាស់បំណិនផ្តល់ប្រឹក្សា ដើម្បីកសាង រក្សា និងបញ្ចប់កិច្ចសន្ទនា
- ប្រើប្រាស់បំណិនប្រឹក្សាយោបល់ដោយស្មារតីសហការ។

## គ. សេវាការងារបណ្តាញ

### គ.១. កិច្ចអន្តរាគមន៍ក្នុងសេវាឆ្លើយតប

- ប្រើប្រាស់វិធីសាស្ត្រឆ្លើយតប និងអន្តរាគមន៍សមរម្យ ស្របតាមតម្រូវការរបស់សិស្សម្នាក់ៗ ក្រុមសិស្សនីមួយៗ ឬសហគមន៍សាលារៀន មុនពេល អំឡុងពេល និងក្រោយពេលមានបញ្ហាវិបត្តិ
- ទាក់ទងក្រុមគ្រួសារសិស្ស សាលារៀនពាក់ព័ន្ធ អាជ្ញាធរ និងសហគមន៍ដែលមានវិជ្ជាជីវៈ ក្នុងស្ថានភាពនៃបញ្ហាវិបត្តិ។

### គ.២. ការចូលរួមរបស់គ្រួសារនិងសហគមន៍ និងប្រព័ន្ធជំនួយ

- កសាង រៀបចំ និងអនុវត្តការងារបណ្តាញ
- កសាង និងរក្សាបណ្តាញ ដើម្បីបង្កើតទំនាក់ទំនងរវាងសាលារៀន ទីកន្លែងប្រកបអាជីវកម្ម គ្រឹះស្ថាន/មជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល និងសហគមន៍ជុំវិញ
- សហការជិតស្និទ្ធជាមួយគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន មាតាបិតា និងអ្នកអាណាព្យាបាលសិស្ស សាលារៀនផ្សេងៗទៀត និងអាជ្ញាធរពាក់ព័ន្ធ
- ចែករំលែកបច្ចេកទេសក្នុងការគាំទ្រដល់ការសិក្សារបស់សិស្សជាមយយអាណាព្យាបាលសិស្ស គ្រូបង្រៀន និងបណ្តាអង្គការក្នុងសហគមន៍
- ផ្សព្វផ្សាយកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ទៅដល់សិស្សដែលពាក់ព័ន្ធទាំងអស់
- រៀបចំវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាចែករំលែកបទពិសោធន៍ផ្នែកប្រឹក្សាយោបល់ និងផ្សព្វផ្សាយករណីជោគជ័យនានា ដល់សិស្ស
- ណែនាំសិស្សទៅកាន់អ្នកមានវិជ្ជាជីវៈ និងធនធានពាក់ព័ន្ធក្នុងសហគមន៍ នៅពេលណាចាំបាច់ ដើម្បីឆ្លើយតបនឹងតម្រូវការផ្សេងៗទៀតរបស់ពួកគេ
- កៀរគរធនធានពីសហគមន៍ និងអ្នកពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធី។

## ៤.៣. គុណសម្បត្តិរបស់គ្រូប្រឹក្សាតាមសាលារៀន

### ៤.៣.១. គុណសម្បត្តិមូលដ្ឋាន

ត្រូវមានបំណិនដូចខាងក្រោម ដើម្បីអនុវត្តការងារមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាបាន៖

- បំណិនអង្កេត និងស្តាប់ដ៏សកម្ម
- បំណិនវិភាគ និងបំណិនពិចារណាល្អិតល្អន់
- បំណិនចរចារ និងអន្តរាគមន៍
- បំណិនដោះស្រាយបញ្ហា
- បំណិនសិក្សា
- បំណិនផ្ទាល់ខ្លួន (Personal Skills)
- បំណិនផ្នែកសង្គម
- បំណិនរៀបចំ និងសម្របសម្រួល
- បំណិនទំនាក់ទំនងលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់
- បំណិនធ្វើបទបង្ហាញសម្រាប់កម្មវិធីមួយចំនួនដូចជា ការបណ្តុះបណ្តាលបន្តរបស់គ្រូ ព្រឹត្តិការណ៍មាតាបិតាសិស្សនិងសហគមន៍ និងបទបង្ហាញអំពីរបាយការណ៍លទ្ធផលមួយចំនួនជូនគណៈគ្រប់គ្រងសាលារៀន ឬសិស្សានុសិស្ស
- បំណិនគ្រប់គ្រងពេលវេលា ដោយប្រើប្រាស់ឧបករណ៍ និងបច្ចេកទេស ដើម្បីរៀបចំផែនការ និងកាលវិភាគការងារផ្ទាល់ខ្លួន និងសកម្មភាពមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- បំណិនសំយោគចំណុចស្របគ្នា ដើម្បីជំរុញកិច្ចព្រមព្រៀងជាក្រុម និងដើម្បីសម្រេចគោលដៅក្រុម
- បំណិនកុំព្យូទ័រមូលដ្ឋាន និងការបញ្ជាផ្នែកបច្ចេកវិទ្យាដែលកំពុងរីកចម្រើននាពេលបច្ចុប្បន្ន ដូចជា ការប្រើប្រាស់អ៊ីនធើណិត ទិន្នន័យផ្អែកលើការស្រាវជ្រាវតាមអ៊ីនធើណិត ឧបករណ៍ប្រមូលទិន្នន័យ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យ
- ផ្នត់គំនិតរីកចម្រើនចំពោះការអភិវឌ្ឍវិជ្ជាជីវៈ និងសមត្ថភាពផ្ទាល់ខ្លួន។

### ៤.៣.២. គុណសម្បត្តិផ្នែកបច្ចេកទេស

ត្រូវមានសមត្ថភាពផ្នែកបច្ចេកទេសដូចខាងក្រោម ដើម្បីអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សាប្រកបដោយប្រសិទ្ធភាព៖

ក. វិជ្ជាសម្បទា

- មានចំណេះដឹងអំពីប្រព័ន្ធអប់រំកម្ពុជា និងយល់ដឹងអំពីឥទ្ធិពលផ្នែកវប្បធម៌ សង្គម និងនយោបាយលើដំណើរការវិស័យអប់រំ
- យល់ដឹងអំពីគោលការណ៍ក្រមសីលធម៌របស់វិជ្ជាជីវៈជាគ្រូប្រឹក្សាតាមសាលារៀន និងទិដ្ឋភាពគោលការណ៍ច្បាប់ ទាក់ទងនឹងតួនាទីរបស់គ្រូប្រឹក្សាតាមសាលារៀន
- យល់ដឹងច្បាស់អំពីកម្មវិធីសិក្សាផ្នែកមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- យល់ដឹងអំពីទ្រឹស្តីអភិវឌ្ឍ និងទ្រឹស្តីនានាទាក់ទងនឹងការសិក្សា

- ស្គាល់បុគ្គលិកលក្ខណៈរបស់សិស្ស និងរបៀបរៀនខុសៗគ្នារបស់សិស្ស
- ដឹងអំពីបច្ចេកទេសគាំទ្រសិស្សដែលមានតម្រូវការពិសេស
- ដឹងអំពីឱកាសការងារក្នុងសហគមន៍ និងក្នុងប្រទេស និងទំនោរការងារនាពេលអនាគត
- យល់ដឹងអំពីឱកាសអប់រំបន្ត និងទំនោរនានាក្នុងវិស័យអប់រំ។

ខ. បំណិនសម្បទា

- ប៉ិនប្រសប់ក្នុងការប្រើប្រាស់ទ្រឹស្តីប្រឹក្សាអាជីព និងបច្ចេកទេសក្នុងកាលៈទេសៈផ្សេងៗ ដូចជាក្នុងពេលផ្តល់ប្រឹក្សាទល់មុខម្នាក់ទល់ម្នាក់ ជាក្រុមតូចៗ និងក្នុងពេលបង្រៀនម៉ោងមគ្គុទ្ទេសក៍ក្នុងថ្នាក់ ជាដើម
- ចេះប្រើបច្ចេកវិទ្យាផ្សេងៗ ដើម្បីសម្របសម្រួលក្នុងការផ្ទេរសេវាប្រឹក្សាយោបល់
- មានបំណិនកសាងភាពជាដៃគូ និងការកសាងបណ្តាញ
- មានបំណិនមូលដ្ឋានក្នុងការសរសេររបាយការណ៍ និងការសិក្សាស្រាវជ្រាវ
- មានបំណិនក្នុងការបង្រៀន និងគ្រប់គ្រងថ្នាក់រៀន
- ប្រើប្រាស់បំណិនស្តាប់ និងឆ្លើយតបបានសមស្រប ទាំងការធ្វើទំនាក់ទំនងដោយប្រើពាក្យសម្តី និងមិនប្រើពាក្យសម្តី ក្នុងពេលបំពេញតួនាទី
- និយាយ និងផ្តល់ព័ត៌មានច្បាស់ និងចំៗ ចៀសវាងប្រើពាក្យមិនច្បាស់លាស់ និងពាក្យសព្ទស្មុគស្មាញពិបាកយល់
- ប្រើប្រាស់បំណិនផ្តល់ប្រឹក្សាប្រកបដោយប្រសិទ្ធភាព
- ផ្តល់ពេលឯកជន និងសុវត្ថិភាព ដល់សិស្សដើម្បីពួកគេអាចរៀបរាប់អំពីទុក្ខកង្វល់ និងក្តីបារម្ភផ្សេងៗ
- បំពេញការងារដោយស្មារតីសហការ និងផ្តល់ការជំរុញលើកទឹកចិត្ត និងគាំទ្រសុខមាលភាពរបស់អ្នកដទៃ
- ស្គាល់ និងបង្ហាញបំណិនស្តាប់ផ្ទាល់ខ្លួន ដូចជា គំនិតយល់ឃើញ អារម្មណ៍ និងបញ្ហានានា ការគិតដល់អ្វីដែលត្រូវនិយាយ ការវិនិច្ឆ័យ និងបុរេវិនិច្ឆ័យ
- ប្រើប្រាស់បំណិនផ្តល់ប្រឹក្សា គោលការណ៍ និងគុណតម្លៃនៃបំណិនផ្តល់ប្រឹក្សាក្នុងផ្នែកទំនាក់ទំនងផ្សេងៗទៀត តាមរយៈការទូរសព្ទនិងការផ្ញើសារ អ៊ីនធើណិត និងបណ្តាញសង្គម។

គ. ចរិយាសម្បទា

- ចេះសម្របការងារជាមួយក្រុមសិស្សផ្សេងៗគ្នា ដោយផ្អែកលើអត្តចរិត ដូចជា ប្រវត្តិជាតិពន្ធុ ភេទ សាសនា និងបញ្ហាជីវភាពគ្រួសារ ជាដើម
- ជួយសិស្សដោយក្តីសប្បុរសនិងការយកចិត្តទុកដាក់ ក្តីមេត្តានិងការគិតគូរពិចារណា សុចរិតភាព ភាពអំណត់អត់ធ្មត់ និងភាពចាស់ទុំផ្នែកអារម្មណ៍។

## ៤.៤ ក្រមសីលធម៌វិជ្ជាជីវៈគ្រូប្រឹក្សាតាមសាលារៀន

### ៤.៤.១ ក្រមសីលធម៌ចំពោះសិស្ស

- គោរពសិទ្ធិឯកជនភាពរបស់សិស្ស

- គោរពតម្លៃ និងជំនឿផ្ទាល់ខ្លួនរបស់សិស្ស
- មានមូលដ្ឋានព័ត៌មានអំពីការអប់រំ ការសិក្សា អាជីព មុខរបរ តម្រូវការបុគ្គល និងសង្គម ដើម្បីលើកកម្ពស់ការអភិវឌ្ឍគុណសម្បទារបស់សិស្ស
- សិក្សាស្រាវជ្រាវអំពីចំណេះដឹងផ្នែកច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធនឹងសិស្ស ក្នុងគោលបំណងការពារ និងផ្តល់ព័ត៌មានទាក់ទងនឹងផ្នែកទាំងនោះដល់សិស្ស
- បញ្ជាក់ប្រាប់សិស្សអំពីវត្ថុបំណង គោលដៅ បច្ចេកទេសផ្សេងៗ ដែលមានទំនាក់ទំនងទៅនឹងដំណើរការកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- ពន្យល់ និងរក្សានូវការណ៍សម្ងាត់ និងដែនកំណត់នៃការរក្សាការណ៍សម្ងាត់ ដែលរួមមាន៖ ដែនកំណត់ផ្លូវច្បាប់ចំពោះការរក្សាការណ៍សម្ងាត់ ដូចជាការការពារសន្តិសុខសណ្តាប់ធ្នាប់ និងដែនកំណត់ផ្នែកក្រមសីលធម៌ចំពោះការរក្សាការណ៍សម្ងាត់ ដូចជាហានិភ័យនៃគ្រោះថ្នាក់ជាដើម
- ផ្តល់ការប្រឹក្សាដោយមិនផ្អែកលើទំនាក់ទំនងបុគ្គលផ្ទាល់ខ្លួន (ឧទាហរណ៍៖ សមាជិកគ្រួសារ មិត្តជិតស្និទ្ធ ឬអ្នកមានទំនាក់ទំនងទៅនឹងគ្រូប្រឹក្សាផ្ទាល់) ដែលនឹងអាចជះឥទ្ធិពលដល់វត្ថុបំណងរបស់អ្នកផ្តល់ប្រឹក្សា និងអាចបង្កើតបញ្ហាប្រឈមដល់សិស្ស
- គាំទ្រ និងការពារកម្មវិធីអប់រំ ប្រឆាំងនឹងការរំលោភសិទ្ធិកុមារ និងបញ្ហាយេនឌ័រ។

### ៨.៨.២ ក្រមសីលធម៌ចំពោះគ្រឹះស្ថានសិក្សា និងសហការីរួមអាជីព

- គោរពគោលការណ៍ បទបញ្ជា ការចាត់តាំងរបស់សាលារៀន
- គាំទ្រ និងផ្សារភ្ជាប់ទំនាក់ទំនងរវាងកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ទៅនឹងបេសកកម្មសាលារៀន
- កសាងកិច្ចសហការល្អ ជាមួយបុគ្គលិកអប់រំក្នុងអង្គភាព ដើម្បីលើកកម្ពស់ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា
- ប្រកាន់ខ្ជាប់នូវគោលការណ៍រក្សាការសម្ងាត់ ភាពខុសគ្នារវាងព័ត៌មានសាធារណៈ និងព័ត៌មានឯកជន
- ផ្តល់ព័ត៌មានដល់គណៈគ្រប់គ្រងសាលារៀន អំពីស្ថានភាពទាំងឡាយណាដែលអាចបង្កផលប៉ះពាល់ដល់ គោលការណ៍ច្បាប់ បទបញ្ជា ទ្រព្យសម្បត្តិសាលារៀន ឬបុគ្គលិកសាលារៀន
- ទទួលយកយោបល់កែលម្អការអនុវត្តសេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ពីបុគ្គលិកអប់រំរួមអាជីព។

### ៨.៨.៣ ក្រមសីលធម៌ចំពោះមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងសហគមន៍

- ផ្តល់នូវព័ត៌មានពាក់ព័ន្ធត្រឹមត្រូវពេញលេញអំពីសិស្ស ដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស
- គោរព និងរក្សាការសម្ងាត់របស់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស

- គោរពដល់សិទ្ធិ និងការទទួលខុសត្រូវរបស់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស ចំពោះកូនៗ របស់ពួកគាត់ ព្រមទាំងបង្កើតទំនាក់ទំនង និងកិច្ចសហការល្អជាមួយពួកគាត់ ដើម្បីការអភិវឌ្ឍគុណសម្បទារបស់សិស្ស
- សហការជាមួយភ្នាក់ងារ អង្គភាព និងបុគ្គលទាំងឡាយក្នុងសហគមន៍ ដែលមានទំនាក់ទំនងទៅនឹងតម្រូវការរបស់សិស្ស
- សហការជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ ដើម្បីបង្កើនការចូលរួមគាំទ្រដល់ការអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា នៅក្នុងសាលារៀន។

### ៤.៤.៤ ក្រមសីលធម៌ចំពោះវិជ្ជាជីវៈ និងខ្លួនឯង

- គោរពតួនាទីភារកិច្ចផ្ទាល់ខ្លួន ជាគ្រូប្រឹក្សាតាមសាលារៀន ក្នុងដែនសមត្ថកិច្ចវិជ្ជាជីវៈ និងមានការទទួលខុសត្រូវលើការប្រព្រឹត្តរបស់ខ្លួន
- តាមដានការប្រព្រឹត្ត និងឥទ្ធិពលរបស់ខ្លួន ដោយមិនត្រូវធ្វើសកម្មភាពទាំងឡាយណា ដែលមានផលប៉ះពាល់ដល់សិស្ស និងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន
- ពង្រឹង និងអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន លើចំណេះដឹងទូទៅ ព័ត៌មានទីផ្សារការងារ ជំនាញទន់ ដើម្បីលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈជាប្រចាំ
- ប្រកាន់យុត្តិធម៌ តម្លាភាពក្នុងអនុវត្តកិច្ចការងារ
- មិនរើសអើងជាតិសាសន៍ ពណ៌សម្បុរ វប្បធម៌ ជំនឿ ភេទ និងកាយសម្បទា
- មិនដើរតួជាអន្តរការី ដើម្បីផលប្រយោជន៍អ្វីមួយពីភាគីទី៣។

## ៤.៥ លទ្ធផលការងារ

លទ្ធផលរំពឹងទុក និងផលជះពីការងាររបស់គ្រូប្រឹក្សាតាមសាលារៀន មានដូចខាងក្រោម៖

- ការផ្លាស់ប្តូរជាវិជ្ជមានផ្នែកអកប្បកិរិយា និងលទ្ធផលសិក្សារបស់សិស្ស
- កម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងដែលមានការសហការគ្នា អាចផ្តល់នូវផលជះជាវិជ្ជមានដល់សិស្សានុសិស្សគ្រប់រូប ប៉ុន្តែសេវាមិនត្រូវផ្តល់តែចំពោះសិស្សដែលគេអាចមើលដឹងពីតម្រូវការ និងផ្តល់តែទៅតាមករណីរបស់សិស្សម្នាក់ៗនោះឡើយ
- ការកើនឡើងនៃការចូលរួមរបស់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស និងការចូលរួមរបស់សហគមន៍ ក្នុងការគាំទ្រការសិក្សារៀនសូត្រ និងការរៀបចំផែនការអាជីពរបស់សិស្ស
- ការសម្រេចចិត្តដោយមានការពិភាក្សា និងការស្វែងយល់អំពីខ្លួនឯងដោយមានការជួយជ្រោមជ្រែងពីគ្រូ នាំឱ្យសិស្សទទួលបាននូវការអប់រំ និងជម្រើសអាជីពប្រកបដោយអត្ថន័យ និងត្រូវនឹងឧបនិស្ស័យផ្ទាល់ខ្លួន ព្រមទាំងឈានដល់ការពេញចិត្ត និងជោគជ័យអាជីពអនាគតរបស់ខ្លួន
- ការប្រមែប្រមូលព័ត៌មានពាក់ព័ន្ធជាប្រព័ន្ធ ជួយពង្រីកខ្លឹមសារកម្មវិធីសិក្សាស្នូលផ្នែកមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា និងធានាបាននូវប្រសិទ្ធភាពកម្មវិធី ដូចជាការកំណត់សិស្សគោលដៅដើម្បីផ្តល់អន្តរាគមន៍នានា និងដើម្បីអាចបំពេញបាននូវចន្លោះផ្សេងៗ

- ការផ្តល់ប្រឹក្សាតាមសាលារៀន គឺជាសមាសភាគមួយក្នុងការកិច្ចគាំពារនានា ដោយបញ្ចូលនូវប្រភេទជំនួយផ្សេងៗ ដែលសិស្សទាំងអស់អាចទទួលបានគ្រប់ៗគ្នា
- ដំណាក់កាលឆ្លងភូមិសិក្សាដោយសុវត្ថិភាព និងមានការគាំទ្រ ជួយទប់ស្កាត់សិស្សអវត្តមានបញ្ហាបរាជ័យក្នុងការសិក្សា និងការបោះបង់ការសិក្សា។ ការគាំទ្រត្រូវពង្រីកដល់ដំណាក់កាលដែលសិស្សឆ្លងភូមិសិក្សា ឬចូលទីផ្សារការងារបន្ទាប់ពីបញ្ចប់ការសិក្សានៅមធ្យមសិក្សា។

## ឯកសារយោង៖


- American School Counselor Association (2019). ASCA School Counselor Professional Standards & Competencies. Alexandria, VA: Author.
- the British Association for Counselling and Psychotherapy (2020). A guide to the BACP counselling skills competence framework: The competences required to use counselling skills in a range of different roles and settings. Retrieved from http://www.bacp.co.uk/